**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**

លេខៈ ៥១៧ អយក.ប្រក

# ប្រ ក ា ស

## ស្តីពីការបើកអនុវិទ្យាល័យ អូរចំណារ
## ស្ថិតនៅក្នុងសង្កាត់អូរឧកញ៉ាហេង ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤_១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍សង្កាត់អូរឧកញ៉ាហេង ខណ្ឌព្រៃនប់ ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០០៥ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលក្រុងព្រះសីហនុ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

**ស ំ រ េ ច**

**ប្រការ ១ :** អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ « អូរចំណារ » ស្ថិតនៅក្នុងសង្កាត់អូរឧកញ៉ាហេង ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ចាប់ពីឆ្នាំសិក្សា ២០០៥_២០០៦ តទៅ ។

**ប្រការ ២ :** អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

**ប្រការ ៣ :** នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាក្រុងព្រះសីហនុ និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៥

បណ្ឌិត កុល ផេង

<u>កន្លែងទទួល</u> :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន"
- សាលាក្រុងព្រះសីហនុ " ដើម្បីជាពត៌មាន"
- ដូចប្រការ ៤
- កាលប្បវត្តិ_ឯកសារ នា.មចទ

C:\New school\Lower-New.doc